**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅសៀមរាប , ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០២២ រវាង ៖

ភាគីសណ្ឋាគារ ៖ តំណាងដោយ លោកស្រី **ហាម សាឡួន** ថ្ងៃ ខែ ឆ្នាំកំណើត 03-06-1985 អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ៖ 180889813 ចុះថ្ងៃទី 25-05-2016 អាសយដ្ឋាន ៖ ផ្ទះលេខ ផ្លូវ ភូមិ សាលាកន្សែង សង្កាត់ ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ក្រោយនេះហៅកាត់ថាភាគី«ក» ។

ភាគីបុគ្គលិកសណ្ឋាគារ៖ តំណាងដោយ ប្រត្តិភូបុគ្គលិក និងតំណាងបុគ្គលិកមួយចំនួន ក្រោយនេះហៅកាត់ថា ភាគី«ខ» ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចព្រមព្រៀង ស្តីពីការព្យួរកិច្ចសន្យាការងារ ដូចមានខ្លឹមសារខាងក្រោម ៖**

## កម្មវត្ថុ

ប្រការ ០១៖ ភាគី«ក»យល់ព្រមព្យួរកិច្ចសន្យាការងារឱ្យ ឯភាគី«ខ»ក៏យល់ព្រមព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៤៥នាក់ (ស្រី ២៥នាក់) នៃសណ្ឋាគារជាតិថាតា ក្នុងភូមិស្ទឹងថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។

## អាណត្តិជួលនៃការព្យួរ

ប្រការ ០២៖ អាណត្តិជួលមានរយៈពេល៥៩(ហាសិបប្រាំបួន)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០២២ រហូតទៅដល់ត្រឹមថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២២ ។

## សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី«ក»

ប្រការ ០៣៖ ទោះបីព្យួរកិច្ចសន្យាការងារឱ្យភាគី«ខ»ហើយក៏ដោយ ក៏ភាគី«ក»មានសិទ្ធិបន្តកិច្ចសន្យាវិញមុនពេលកំណត់ ក្នុងករណីសណ្ឋាគារមានភ្ញៀវអាចដំណើរការវិញ ដោយភាគី«ក»ជូនដំណឹងដោយផ្ទាល់មាត់ ឬជាលាយ- លក្ខណ៍អក្សរដល់ភាគី«ខ» ។

ប្រការ ០៤៖ កាតព្វកិច្ចរបស់ភាគី«ក» រួមមាន ៖

៤.ក- រក្សាកិច្ចសន្យាការងារ និងអត្ថប្រយោជន៍ទាំងអស់នៅក្នុងកិច្ចសន្យាកន្លងមក ។

៤.ខ- ធានាដោះស្រាយលិខិតរដ្ឋបាលទាក់ទងនិងការព្យួរកិច្ចសន្យាការងារនេះ ។

៤.គ- មិនធានាខុសត្រូវលើកិច្ចសន្យាបើ ភាគី«ខ» មិនមានសុខមាលភាពអាចបំពេញភារៈកិច្ចជូនភាគី«ក» ពេលដែលភាគី«ក»ត្រូវការ ។

៤.ឃ- មិនទទួលខុសត្រូវការប្រព្រឹត្តខុសច្បាប់របស់បុគ្គលក្នុងកំឡុងព្យួរកិច្ចសន្យាការងារនេះទេ ។

សណ្ឋាគារ ជាតិថាតា អង្គរ
CHEATHATA ANGKOR HOTEL

## សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី«ខ»

ប្រការ ០៥៖ មានសិទ្ធិពេញលេញក្នុងស្វែងរកការងារថ្មី និងបញ្ចប់កិច្ចសន្យាការងារជាមួយភាគី«ខ» ដោយមិនទាមទាសំណងអ្វីៗទាំងអស់ ។

ប្រការ ០៦៖ កាតព្វកិច្ចរបស់ភាគី«ខ» រួមមាន ៖

៦.ក- គ្រប់គ្រង ថែរក្សាស្មារតី សុខមាលភាពផ្ទាល់ខ្លួនដើម្បីអាចបំរើការងារបានវិញនៅពេលភាគី«ក»ត្រូវការចូលបំរើការងារវិញ។

៦.ខ- ភាគី«ខ»ធានាការចូលរួមដោះស្រាយបញ្ហាទាក់ទង ពត៌មានការងារ និងការព្យួរកិច្ចសន្យាការងារ ។

៦.គ- ភាគី«ខ»ធានាថា ខ្លួនមានទំនាក់ជាប់ជានិច្ចជាមួយសណ្ឋាគារ ដើម្បីទទួលរាល់ពត៌មានដែលផ្តល់ដោយសណ្ឋាគារ ។

៦.ឃ- ទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខច្បាប់ ក្នុងករណីមានបាតុភាពខុសនឹងច្បាប់នៅក្នុងពេលព្យួរការងាររបស់ខ្លួន។

ប្រការ ០៧៖ ក្នុងករណីមិនមានលទ្ធភាព រឺសុខភាពមិនល្អ នោះភាគី«ខ»យល់ព្រមបញ្ចប់កិច្ចសន្យា និងមិនទាមទារយកវិញអ្វីឡើយ ។

## ការបញ្ចប់កិច្ចព្រមព្រៀង

ប្រការ ០៨៖ ក្នុងករណីមានបំណងបន្ត ភាគី«ក» ត្រូវជូនដំណឹងឱ្យភាគី«ខ»យ៉ាងតិច៣(បី)ថ្ងៃមុនថ្ងៃបញ្ចប់កិច្ចព្រមព្រៀងឯភាគី«ខ»ក៏ត្រូវឆ្លើយតបវិញក្នុងរយៈពេល០៣(បី)ថ្ងៃ ។

ប្រការ ០៩៖ នៅពេលបញ្ចប់អាណត្តិ ភាគី«ខ»ត្រូវធ្វើការជូនភាគី«ក»វិញ ។

## ការដោះស្រាយវិវាទ និងកែប្រែកិច្ចព្រមព្រៀង

ប្រការ ១០៖ ក/-ករណីមានប្រធានស័ក ប្រទេសមានសង្រ្គាម ឬហេតុកលយុគណាមួយ ដែលជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការអាជីវកម្ម នោះភាគីទាំងពីរ ត្រូវជួបពិភាក្សាគ្នារកដំណោះស្រាយសមស្រប ផ្អែកតាមសភាពជាក់ស្តែង និងស្មារតីយោគយល់គ្នាទៅវិញទៅមក ។

ខ/-ក្នុងករណីមានវិវាទកើតឡើងនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យានេះ ភាគីទាំងពីរត្រូវជួបគ្នា ដើម្បីពិភាក្សាដោះស្រាយឈរលើមូលដ្ឋានស្រុះស្រួលទៅវិញទៅមក។ ប្រសិនបើគ្មានដំណោះស្រាយដោយកិច្ចពិភាក្សាក្នុងរយៈពេលយ៉ាងយូរក្នុងរយៈពេល៣(បី)ខែ នោះបញ្ហាវិវាទត្រូវបញ្ជូនទៅដោះស្រាយតាមផ្លូវច្បាប់នៅស្ថាប័នមានសមត្ថកិច្ច ឬតុលាការខេត្តសៀមរាប ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១១៖ រាល់ការសម្រេចកែប្រែ ឬបន្ថែមប្រការណាមួយពាក់ព័ន្ធនឹងកិច្ចសន្យានេះនឹងចាត់ទុកជាបានការ លុះត្រាតែមានការឯកភាពយល់ព្រមជាលាយលក្ខណ៍អក្សររវាងភាគីទាំងពីរ។

ប្រការ ១២៖ កិច្ចសន្យានេះធ្វើឡើងចំនួន០៥(ប្រាំ)ច្បាប់ មានសុពលភាពចាប់ពីថ្ងៃដែលភាគីទាំងពីរបានផ្តិតមេដៃជាសម្គាល់តទៅ ហើយកិច្ចសន្យានេះត្រូវបានរក្សាទុកដោយ ៖

សណ្ឋាគារ ជាតិថាតា អង្គរ
CHEATHATA ANGKOR HOTEL

– ភាគី«ក» .................................. ចំនួន ០១ច្បាប់

– ភាគី«ខ» .................................. ចំនួន ០១ច្បាប់

– ០៣(បី) សំរាប់មន្ទីរការងារ

**ស្នាមមេដៃស្តាំ**

**ភាគី«ខ»** **ភាគី«ក»**

**ហម សាឡុន**